# តើអ្នកជឿលើព្រះយេស៊ូវគួរផឹកគ្រឿងស្រវឹងឬទេ?

## លំនាំដើម

មានប្រធានបទមួយដែលតែងតែនាំអ្នកជឿលើព្រះយេស៊ូវពិភាក្សាគ្នាហើយឈ្លោះគ្នាទៀតគឺការផឹកស្រា។រឿងនេះសំខាន់ហើយអ្នកជឿលើព្រះទាំងឡាយគួរស្គាល់ព្រះគម្ពីរដែលទាក់ទងជាមួយការផឹកស្រាហើយយល់អំពីរបៀបណាដែលអ្នកជឿគួរអនុវត្តតាមដែរ។គោលបំណងមេរៀនទាំងនេះគឺឆ្លើយតបតាមសំណួរនេះថា «តើអ្នកជឿលើព្រះយេស៊ូវគួរតែផឹកស្រាដូចគេដែរ ឬទេ? បើផឹកបាន យើងគួរផឹកបែបណា? បើមិនគួរផឹក ហេតុអ្វីមិនគួរផឹក?»

តាមធម៌ព្រះពុទ្ធសាសនា ហើយតាមច្បាប់សាសនាអីស្លាម ការញ៉ាំស្រាជាអំពើបាប ដូច្នេះហើយសាសនាទាំងពីរហាមឃាត់ កុំឲ្យញ៉ាំសុរា។តើអ្នកជឿលើព្រះយេស៊ូវទៅវិញ? តើពួកគ្រិះស្ទានគួរផឹកស៊ីជាមួយគេបានដែរ ឬទេ?

មនុស្សលោកសឹងតែទាំងអស់ឯកភាពថា ការស្រវឹងស្រា គឺបាប។គ្មានមនុស្សល្អណា ដែលនឹងប្រកែកថាស្រវឹងស្រាល្អនោះទេពីព្រោះយើងទាំងអស់គ្នាដឹងហើយធ្លាប់ឮ សុរាទោសហើយផលអាក្រក់ផ្សេងៗទៀតពីព្រោះការស្រវឹងស្រាដូចជាអំពើហឹង្សាការរំលោភសហាយស្មន់ការគ្រោះថ្នាក់ អំពើអាម៉ាស់។ភាគច្រើនដឹងថែមទៀតថា ផឹកស៊ីច្រើនឬកើតរោគស្រា បំផ្លាញរូបកាយ ជាពិសេសខួរក្បាលរបស់យើង។

នៅពេលដែលយើងអានព្រះគម្ពីរយើងចាប់យល់ថាព្រះអង្គបង្គាប់អ្នកជឿលើទ្រង់ឲ្យជៀសផុតពីការស្រវឹងស្រា

*«កុំឲ្យស្រវឹងស្រាដែលនាំឲ្យព្រើលចិត្តឡើយ តែចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ»*

(អេភេសូ ៥:១៨)

ព្រះគម្ពីរបានបង្រៀនយើងយ៉ាងច្បាស់ថាការស្រវឹងស្រានាំឲ្យមានការគ្រោះថ្នាក់ និង អំពើអាម៉ាស់ជាច្រើន

*«តើអ្នកណាមានសេចក្ដីពិបាកចិត្តតើអ្នកណាកើតទុក្ខព្រួយ តើអ្នកណាមានសេចក្ដីទាស់ទែងគ្នា តើអ្នកណាត្អូញត្អែរ តើអ្នកណាត្រូវរបួសឥតហេតុ តើអ្នកណាមានភ្នែកក្រហម ៣០ គឺជាពួកអ្នកដែលអង្គុយផឹកស្រាជាយូរ ឯពួកអ្នកដែលស្វែងរកស្រាលាយនោះឯង ៣១ កុំឲ្យមើលស្រាទំពាំងបាយជូរក្នុងកាលដែលមានពណ៌ក្រហមគឺក្នុងកាលដែលព្រួចពពុះនៅក្នុងកែវ ហើយហូរចុះទៅដោយស្រួលនោះឡើយ ៣២ ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ ហើយអុចដូចជាពស់ហនុមានផង ៣៣ ភ្នែកឯងនឹងឃើញស្រីដទៃ ហើយចិត្តឯងនឹងពោលសេចក្ដីខូចអាក្រក់ដែរ ៣៤ អើ ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្ដាលសមុទ្រ ឬដូចជាមនុស្សដែលដេកនៅលើចុងដងក្ដោង ៣៥ ឯងនឹងថា គេបានវាយអញ តែអញមិនបានឈឺសោះ គេបានសំពងអញ តែអញមិនដឹងទេ តើអញនឹងភ្ញាក់ឡើងវិញដល់កាលណាហ្ន៎ អញនឹងទៅរកផឹកទៀត។»* (សុភាសិត ២៣:២៩-៣៥)

ព្រះគម្ពីរផ្សេងៗទៀតបង្ហាញថា អ្នកណាដែលមិនព្រមលះចោលអំពើបាបធ្ងន់ ដូចជាការស្រវឹងស្រាគឺជាអ្នកដែលមិនទាន់ស្គាល់ព្រះហើយគ្មានចិត្តគោរពព្រះអង្គទេ។អ្នកណាដែលត្រូវបានសង្គ្រោះក្នុងព្រះយេស៊ូវអ្នកនោះមិនចង់បន្តក្នុងអំពើបាបនោះទៀតទេ ពីព្រោះបានលាងស្អាតហើយ

*«តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ១០ ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះដៀល និងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ ១១ ឯពួកអ្នករាល់គ្នាខ្លះ ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះដែរ តែបានលាងស្អាតហើយ ក៏បានញែកជាបរិសុទ្ធ ហើយរាប់ជាសុចរិតផង ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា។»* (១កូរិនថូស ៦:៩-១១)

អ្នកដែលចេះតែថា «ខ្ញុំជឿ» ប៉ុន្តែនៅជាប់ក្នុងការស្រវឹងស្រាបញ្ជាក់ឲ្យយើងដឹងថាជំនឿរបស់គាត់មិនពិតទេ

*« រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្ដី កំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ២០ ថ្វាយបង្គំរូបព្រះ មន្តអាគម ស្អប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ២១ ច្រណែន កាប់សំឡាប់ ប្រមឹក ស៊ីផឹកជ្រុល និងការអ្វីទៀត ដែលស្រដៀងនឹងសេចក្ដីទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ»* (កាឡាទី ៥:១៩-២១)

ដូច្នេះយើងឃើញថា រឿងស្រវឹងស្រាជារឿងសំខាន់មួយនៅចំពោះព្រះពីព្រោះអ្នកស្រវឹងស្រាមិនអាចរស់នៅដើម្បីគោរពព្រះអង្គបានទេ។ ការកែប្រែមួយបង្ហាញពីជំនឿពិតប្រាកដរបស់យើង គឺយើងលេងស្រវឹងស្រាហើយចង់ដើរក្នុងជីវិតថ្មី។បើសិនជាមានអ្នកជឿនរណាម្នាក់ក្នុងក្រុមជំនុំដែលមិនព្រមកែប្រែទេព្រះគម្ពីរនាំឲ្យយើងបណ្ដេញអ្នកនោះឲ្យចេញពីក្រុមជំនុំរហូតដល់គាត់ឈប់ប្រព្រឹត្តអំពើបាបដ៏ធ្ងន់នោះ

*«ខ្ញុំបានផ្ញើសំបុត្រផ្ញើមកប្រាប់អ្នករាល់គ្នាថា កុំឲ្យគប់ប្រសព្វនឹងមនុស្សកំផិតឡើយ ១០ តែពាក្យនោះមិនសំដៅចំពោះមនុស្សកំផិតរបស់ផងលោកីយ៍នេះ ឬមនុស្សលោភ មនុស្សប្លន់កំហែង ឬមនុស្សថ្វាយបង្គំរូបព្រះនោះទេ ដ្បិតបើដូច្នោះ នោះត្រូវតែចេញឲ្យផុតពីលោកីយ៍នេះទៅ ១១ គឺខ្ញុំបានសរសេរមកអ្នករាល់គ្នា ដោយន័យយ៉ាងនេះថា បើមានអ្នកណានៅក្នុងពួកជំនុំ ជាមនុស្សកំផិត ឬលោភ ឬថ្វាយបង្គំរូបព្រះ ឬជេរប្រមាថ ជាអ្នកប្រមឹក ឬប្លន់កំហែង នោះមិនត្រូវឲ្យគប់ប្រសព្វនឹងគេឡើយ ក៏មិនត្រូវទាំងបរិភោគជាមួយនឹងគេផង ១២ ដ្បិតតើត្រូវការអ្វីឲ្យខ្ញុំជំនុំជំរះដល់មនុស្សខាងក្រៅ តើអ្នករាល់គ្នាមិនជំនុំជំរះមនុស្សក្នុងពួកជំនុំទេឬអី ១៣ ឯចំណែកពួកអ្នកខាងក្រៅ នោះព្រះនឹងជំនុំជំរះគេ ហើយត្រូវឲ្យអ្នករាល់គ្នាបណ្ដេញមនុស្សអាក្រក់នោះ ពីពួកអ្នករាល់គ្នាចេញ។»*
(១កូរិនថូស ៥:៩-១៣)

ឥឡូវនេះយើងត្រូវសិក្សាព្រះគម្ពីរដែលទាក់ទងនិងការផឹកស្រាដោយមិនស្រវឹងទៅវិញ។តើមានបទគម្ពីណាខ្លះដែលណែនាំយើងឲ្យស្គាល់ព្រះហឫទ័យរបស់ទ្រង់? មុនដែលលោកអ្នកសិក្សាបន្តសូមស្វែងរកប្រាជ្ញាពីព្រះអង្គក្នុងការអធិស្ឋានសិនបន្ទាប់មករៀនបន្តទៀត។

1. <u>ការយល់ច្រឡំ</u>
   **អ្នកខ្លះមានការយល់ច្រឡំហើយសំអាងថាព្រះគម្ពីរមិនហាមឃាត់អ្នកជឿលើព្រះពីការញ៉ាំសុរានោះទេដូច្នេះយើងញ៉ាំសុរាបាន។**

❖ គេថាយើងញ៉ាំសុរាបានពីព្រោះព្រះយេស៊ូវបានប្តូរទឹកទៅជាស្រាទំពាំងបាយជូរ។ព្រះយេស៊ូវធ្វើទីសំគាល់មុនដំបូង នៅភូមិកាណា (យ៉ូហាន ២:១-១១)។ សូមអានគម្ពីរនោះសិន។ នៅពេលនោះព្រះអង្គទាំងសិស្សរបស់ទ្រង់ចូលរួមជប់លៀងអាពាហ៍ពិពាហ៍របស់គេ។ទីសំគាល់ដែលទ្រង់ធ្វើគឺប្តូរទឹកក្នុងពាងទៅជាស្រាទំពាំងបាយជូរទៅវិញ។ហេតុដូច្នេះហើយយើងឃើញថាស្រាទំពាំងបាយជូនោះមិនអាចអាក្រក់បានទេពីព្រោះព្រះយេស៊ូវបានបង្កើតស្រានោះពីទឹកធម្មតាហើយទ្រង់មិនដែលធ្វើបាបសោះ (២កូរិនថូស ៥:២១; ហេព្រើរ ៤:១៤-១៥)។អ្នកខ្លះបើសួរគេថាតើយើងជាអ្នកជឿលើព្រះគួរផឹកសុរាជាមួយគេបាន ឬទេអ្នកនោះតែងតែថាបានពីព្រោះព្រះយេស៊ូវបានប្តូរទឹកទៅជាស្រាទំពាំងបាយជូរ។តើអ្នកគ្រិស្ទានគួរប្រើទីសំគាល់នោះជាភស្តុតាងថា អ្នកជឿគួរញ៉ាំស្រាដែរ ឬទេ? ទេ

❖ គេថា យើងញ៉ាំសុរាបានពីព្រោះព្រះយេស៊ូវបានប្រកាសយ៉ាងច្បាស់ថា ម្ហូបអាហារទាំងអស់ឈ្មោះថាស្អាត។ទ្រង់មានបន្ទូលនេះដើម្បីនាំឲ្យយើងយល់ថាគ្មានអាហារឬគ្រឿងផឹកណាដែលធ្វើឲ្យយើងមិនស្អាតឡើយបាបមកពីក្នុងចិត្តរបស់មនុស្សទេ។មួយទៀតព្រះអង្គមានព្រះហឫទ័យឲ្យអ្នក ជឿ នៅ សម័យសញ្ញាចាស់កាន់ក្រិត្យវិន័យអំពីអាហារដែរ មានសត្វស្អាតហូបបាន ហើយសត្វមិនស្អាតហូបមិនបាន ។ល។

សម័យឥឡូវនេះព្រះអង្គគ្មានក្រិត្យវិន័យអំពីសត្វស្អាតហើយមិនស្អាតទៀតទេ ឧទាហរណ៍៖ ឥឡូវនេះយើងញ៉ាំសាច់ជ្រូកបានប៉ុន្តែសម័យមុនមិនមែនទេ។ *«ទ្រង់មានព្រះបន្ទូលថា តើអ្នករាល់គ្នានៅតែមិនយល់ដែរឬអី តើអ្នករាល់គ្នានឹកមិនឃើញទេឬអីថា របស់អ្វីពីខាងក្រៅដែលចូលក្នុងមនុស្ស នោះពុំអាចនឹងធ្វើឲ្យស្មោកគ្រោកបានទេ ១៩ ដ្បិតរបស់នោះមិនបានចូលទៅក្នុងចិត្ត គឺចូលទៅតែក្នុងពោះប៉ុណ្ណោះ រួចចេញទៅក្នុងបង្គន់ ដូច្នេះ អស់ទាំងអាហារឈ្មោះថា ជារបស់ស្អាតវិញ ២០ ទ្រង់ក៏មានព្រះបន្ទូលថា គឺជាសេចក្តីដែលចេញពីមនុស្សមកទេតើ ដែលធ្វើឲ្យស្មោកគ្រោកនោះ ២១ ដ្បិតនៅពីខាងក្នុង ពីក្នុងចិត្តរបស់មនុស្ស មានចេញអស់ទាំងគំនិតអាក្រក់យ៉ាងនេះ គឺសេចក្តីកំផិត សហាយស្មន់ កាប់សំឡាប់គេ ២២ លួចប្លន់ លោភ ខិលខូច ឧបាយកល អាសអាភាស ភ្នែកអាក្រក់ ជេរប្រមាថ ឆ្មើងឆ្មៃ និងសេចក្តីចំកួត ២៣ គឺសេចក្តីអាក្រក់ទាំងនេះហើយ ដែលចេញពីខាងក្នុងមក ហើយធ្វើឲ្យមនុស្សស្មោកគ្រោកវិញ។»* (ម៉ាកុស ៧:១៨-២៣) ព្រះគម្ពីរ កិច្ចការ ១០:៩-១៦ ទាក់ទងនិងរឿងនេះដែរ។
ខទាំងនេះបង្រៀនថាគ្មានអ្វីៗនៅខាងក្រៅដែលធ្វើឲ្យកូនរបស់ព្រះស្មោគគ្រោកទេដូចស្រាជាដើម។ទឹកស្រាវាមិនអាក្រក់ខ្លួនវាទេ វាក្លាយទៅជាអាក្រក់នៅពេលដែលវាជំរុញមនុស្សឲ្យស្រវឹង។ឧទាហរណ៍៖ សំលៀកបំពាក់សិចស៊ីសាច់ក្រណាត់វាមិនអាក្រក់ខ្លួនវាទេប៉ុន្តែនៅពេលដែលស្រីណាហ៊ានស្លៀកពាក់វារបៀបមិនបិតបាំងខ្លួនដោយអំនួតហើយមិនចេះខ្មាស់គេនៅពេលនោះយើងហៅសំលៀកបំពាក់នោះឈ្មោះថាអាក្រក់។តើព្រះយេស៊ូវមានបន្ទូលទាំងនេះដើម្បីបើកចំហរឲ្យកូនព្រះផឹកស៊ីជាមួយគេឬទេ? ទេ មិនមែនដូច្នេះទេ!

- គេថា យើងញ៉ាំសុរាបានពីព្រោះសាវកប៉ុលបានប្រាប់លោកធីម៉ូថេ ដ៏ជាគ្រូហើយជាអ្នកផ្សាយដំណឹងល្អថាឲ្យគាត់ផឹកស្រាទំពាំងបាយជូរខ្លះ ជាទឹកថ្នាំព្យាបាលជំងឺពោះរបស់គាត់ (១ធីម៉ូថេ ៥:២-៣)។ ដូច្នេះសាវកប៉ុលមិនបាន

រាប់ការផឹកភេសជ្ជៈដែលមានជាតិស្រាជាអំពើបាបជាដាច់ខាតនោះទេ។ តើពាក្យរបស់សាវកប៉ុលនៅពេលនោះគួរនាំឲ្យយើងស្មានថាយើងផឹកស្រាដោយសេរីបានដែរ ឬទេ? ទេ មិនមែនដូច្នេះទេ!យើងនឹងលើកខគម្ពីរនេះមកនិយាយម្តងទៀតក្នុងមេរៀនខាងក្រោម។

- គេថា យើងញ៉ាំសុរាបានពីព្រោះព្រះគម្ពីរ ១ធីម៉ូថេ ៣:១-១៣ ហើយ ទីតុស ១:៥-១១ មិនហាមឲ្យគ្រូផឹកស្រាទេ។ខទាំងនោះមានចែងទុកអំពីគុណសម្បត្តិចាំបាច់សម្រាប់អ្នកដែលយើងតាំងឡើងជាអ្នកដឹកនាំក្នុងក្រុមជំនុំ។ក្នុងបញ្ជីនោះមានពាក្យហាមឃាត់តែកុំឲ្យអ្នកចាស់ទុំនោះចំណូលស្រាប៉ុន្តែឲ្យមានចិត្តនឹងធឹង ដឹងខ្នាត និងធូន់ធូរទៅវិញ ជាអ្នកឥតកន្លែងចាប់ទោសបាន។

តើពាក្យទាំងនេះបើកចំហរឲ្យយើងផឹកស៊ីដូចគេដែរឬទេ? តើអ្នកជឿលើព្រះយេស៊ូវគួរញ៉ាំស្រាបៀរស្រាទឹកត្នោតស្រាស ឬវីស្គីជាមួយគេឬទេ?បើយើងញ៉ាំដោយប្រុងប្រយ័ត្នហើយមិនស្រវឹងខុសទេ? ដើម្បីមានចម្លើយដ៏គ្រប់ហើយត្រឹមត្រូវតាមព្រះគម្ពីរវាជាការសរៈសំខាន់មួយដែលលោកអ្នកយល់អំពីការខុសគ្នារវាងស្រាទំពាំងបាយជូរក្នុងព្រះគម្ពីរហើយសុរាដែលមានលក់ក្នុងទីផ្សារនៅពេលបច្ចុប្បន្ននេះ។

## 2. <u>ការយល់ដឹង</u>

**មានការយល់ដឹងដ៏សំខាន់ដើម្បីយល់ច្បាស់ហើយដោះស្រាយបញ្ហាការផឹកសុរាក្នុងព្រះគម្ពីរបានយើងត្រូវយល់ពីការ ខុសគ្នារវាងស្រាដែលមានលក់នៅស្រុកខ្មែររាល់ថ្ងៃនេះនិងស្រាទំពាំងបាយជូរក្នុងព្រះគម្ពីរ។**

- ស្រាទំពាំងបាយជូរក្នុងព្រះគម្ពីរមានជាតិស្រាមានជាតិអាកុលមែន។អ្នកដែលផឹកស្រាទំពាំងបាយជូរនោះអាចស្រវឹងដែរប៉ុន្តែវាមិនមែនដូចស្រាដែលគេបិតស្រាក្នុងរោងចក្រ ឬតាមផ្ទះ នៅពេលឥឡូវនេះទេ។ នៅសម័យមុននោះពួក

គេក្រមានប្រភពទឹកហើយទឹកមិនសូវស្អាតដោយព្រោះមេរោគដូច្នេះគេប្រើជាតិស្រាដើម្បីសំអាតទឹកនោះហើយទុកប្រើបានយូរ។ លោកទាំងនោះគ្មានភេសជ្ជៈផ្សេងៗទៀត ដូចជាទឹកក្រូចទឹកដូងទឹកដោះគោត្រជាក់ទឹកផ្លែឈើ។ល។ ដែលសំបូរនៅសម័យឥឡូវនេះទេ។

- ស្រាទំពាំងបាយជូរដែលគេបានផលិតកាលពីបុរាណនោះគេលាយស្រានោះជាមួយទឹកច្រើន។ នៅពេលដែលពួកគេបានញាំស្រាទំពាំងបាយជូរនោះ គ្មានអ្នកណាអាចរហ័សស្រវឹងបានទេមួយទៀតដើម្បីស្រវឹងអ្នកនោះត្រូវផឹកស្រានោះច្រើនកែវ។ ដូច្នេះហើយបានជាព្រះគម្ពីរសុភាសិត២៣ ចែងទុកថាអ្នកស្រវឹងជាអ្នកផឹកស្រាជាយូរ

  *«តើអ្នកណាមានសេចក្តីពិបាកចិត្តតើអ្នកណាកើតទុក្ខព្រួយ តើអ្នកណាមានសេចក្តីទាស់ទែងគ្នា តើអ្នកណាត្អូញត្អែរ តើអ្នកណាត្រូវរបួសឥតហេតុ តើអ្នកណាមានភ្នែកក្រហម ៣០ គឺជាពួកអ្នកដែលអង្គុយផឹកស្រាជាយូរ ឯពួកអ្នកដែលស្វែងរកស្រាលាយនោះឯង»*

  ហេតុនេះហើយបានជាលោកធីម៉ូថេអាចផឹកស្រាតិចជាថ្នាំ ហើយមិនខ្លាចស្រវឹងបាន។ប៉ុន្តែមើលលោកធីម៉ូថេមិនចង់ផឹកស្រាទេទាល់តែសរកប៉ុលបង្គាប់គាត់ឲ្យផឹកវាដើម្បីព្យាបាល។

  *«កុំឲ្យផឹកទឹកតែប៉ុណ្ណោះ ត្រូវឲ្យផឹកស្រាទំពាំងបាយជូរបន្តិចផង ដោយព្រោះក្រពះអ្នក និងរោគដែលអ្នកមានជាញយៗ»* (១ធីម៉ូថេ ៥:២៣)

- សូមអានអំពីពាក្យពន្យល់ល្អមួយអំពីរបៀបពួកគេធ្វើស្រានៅសម័យបុរាណ

  *«នៅសម័យបុរាណ មិនទាន់មានបច្ចេកទេសបិតស្រា ដើម្បីចំរើនជាតិអាល់កុល ដូចមានសព្វថ្ងៃនេះនៅឡើយទេ។ ប៉ុន្តែពួកគេបានធ្វើស្រាដោយបញ្ជាន់ផ្លែទំពាំងបាយជូរក្នុងអាង ហើយប្រមូលទឹកផ្លែឈើទុកក្នុងពាង ឬថង់ស្បែកយ៉ាងយូរ*

*ឲ្យឡើងជូរខ្លួនឯងតាមធម្មជាតិ ទើបវាមានជាតិឆ្ងាញ់ និងជាតិអាល់កុលខ្លះផង។ គេច្រូតផ្លែទំពាំងបាយជូរក្នុងមួយឆ្នាំបានតែមួយដងទេ ដូច្នេះ ពួកគេត្រូវការវិធីមួយ ដើម្បីទុកទឹកផ្លែទំពាំងបាយជូរឲ្យបានយូរ យ៉ាងហោចណាស់ រហូតដល់ចំរូតឆ្នាំបន្ទាប់។ បើមិនបានធ្វើស្រាទំពាំងបាយជូរទេ នោះត្រូវបាត់បង់អត្ថប្រយោជន៍ នៃផលអស់ ពីព្រោះវាបានខូច ដោយក្លាយទៅជាទឹកខ្មេះវិញ ដែលមនុស្សផឹកមិនកើត។ មួយវិញទៀត ធ្វើទឹកផ្លែឈើដែលគ្មានជាតិអាល់កុលក៏មិនកើតដែរ ពីព្រោះវា ចាប់ផ្ដើមឡើងជូរតាំងពីខណៈពេលបញ្ចាន់ ហើយនៅគ្រានោះ មិនទាន់ មានបច្ចេកទេសសម្រាប់បង្ខាំងដំណើរឡើងជូរនៅឡើយទេ។ ប៉ុន្តែបើធ្វើស្រាទំពាំងបាយជូរ នោះវាមិនបានខូចទេ ពីព្រោះជាតិអាល់កុលអាចការពារសារជាតិក្នុងវារាប់ឆ្នាំ ហើយមនុស្សផឹកវារាប់ឆ្នាំក៏បានដែរ។ ដូច្នេះពួកគេបានធ្វើស្រាទំពាំងបាយជូរ តាមធម្មជាតិ ដោយបំណងរក្សាទុកភោគផលកសិកម្មដ៏បរិបូរណ៍ក្នុងស្រុកឲ្យបានយូរ ដោយគ្មានបច្ចេកទេសទំនើបសម្រាប់បង្ខាំងដំណើរឡើងជូរ ឬក៏បច្ចេកទេសបិទស្រាសម្រាប់ចំរើនជាតិអាល់កុលផងដែរ។»*

- សូមអានអំពីពាក្យពន្យល់ល្អមួយអំពីរបៀបពួកគេធ្វើស្រានៅសម័យបច្ចុប្បន្ន *«នៅសម័យបច្ចុប្បន្ននេះ ជាទូទៅមនុស្សលែងចាត់ទុកថា ការស្រវឹងជាអំពើអបាយមុខទៀតហើយ ទោះបីជាមនុស្សខ្លះនៅតែរាប់ថាវាជាការមិនល្អក៏ដោយ។ រាប់រយឆ្នាំចុងក្រោយនេះមក គេបានអភិវឌ្ឍមធ្យោបាយ និងបច្ចេកទេសច្រើនណាស់សម្រាប់ចំរើនជាតិអាល់កុលក្នុងស្រា ដើម្បីធ្វើឲ្យមនុស្សកាន់តែមានអារម្មណ៍រំភើបរីករាយនឹងស្រា រួមទាំងឲ្យបានឆាប់ស្រវឹងជាងធម្មតាផង ដូចខាងក្រោមនេះជាដើម៖*

*គេបានច្នៃដើមទំពាំងបាយជូរដោយរើសពូជ ឲ្យបង្កើតផ្លែមានជាតិស្ករលើស ជាងធម្មតា ដើម្បីបង្កើនជាតិអាល់កុលក្នុងស្រា ពីព្រោះនៅពេលដែលគេយកផ្លែ ទំពាំងបាយជូរទៅធ្វើស្រា ជាតិស្ករក្នុងវាក្លាយទៅជាជាតិអាល់កុលទៅវិញ។ ជួនកាល គេបន្ថែមស្ករក្នុងគ្រឿងផ្សំតែម្តង។*

*គេបិតស្រាដោយប្រើប្រាស់ម៉ាស៊ីនមានបច្ចេកទេសខាងគីមីវិទ្យា ដែលបន្ថែម កំដៅ និងសំពាធ ប្រយោជន៍ឲ្យបានបង្កើន ជាតិអាល់កុលក្នុងស្រាឲ្យបានច្រើនជាង ស្រាធម្មជាតិ ហើយឲ្យបានធ្វើវាឆាប់រហ័សជាងធម្មតាដែរ។*

*ក្នុងស្រាប្រភេទខ្លះ គេផ្ទុកទឹកអាល់កុលឈ្មោះ "ethanol" បន្ថែមតែម្តង។*

*គេនិយមបង្កើនជាតិហ្គាស់ក្នុងស្រាដោយវិធីទំនើប ពីព្រោះជាតិហ្គាស់ ក្នុង ស្រាធ្វើឲ្យជាតិអាល់កុលជ្រាបចូលទៅក្នុងចរន្តឈាមលឿនជាងធម្មតា លទ្ធផលគឺធ្វើ ឲ្យមនុស្សបានឆាប់ពុលស្រាជាង។*

*គេធ្វើស្រាក្នុងរោងចក្រ ដែលផលិតស្រាយ៉ាងឆាប់រហ័ស និងច្រើនក្រៃលែង ដើម្បីធ្វើឲ្យស្រាមានតម្លៃទាបក្នុងទីផ្សារ ប្រយោជន៍ឲ្យមនុស្សទូទៅមានលទ្ធភាពទិញ តាមចិត្តរបស់គេចង់បាន។ ធ្វើដូច្នេះ ក្រុមហ៊ុន និងអ្នកលក់ស្រាបានចំណេញច្រើន ណាស់!*

*ដូច្នេះ យើងត្រូវតែសន្និដ្ឋានថា ស្រាដែលគេផលិតដោយប្រើបច្ចេកទេសទំនើបសព្វ ថ្ងៃនេះ មិនដូចស្រាដែលគេបានធ្វើតាមធម្មជាតិនៅសម័យបុរាណនោះទាល់តែ សោះ!»*

ដូច្នេះសុរាដែលមានលក់នៅទីផ្សារាល់ថ្ងៃនេះខុសគ្នាពីស្រាទំពាំងបាយជូរនៅសម័យ បុរាណឆ្ងាយណាស់! សព្វថ្ងៃអ្នកផលិតស្រាអ្នកសុរាជីវិននិងពួកមជ្ឈពាណិជដឹងហើយថា បើផលិតសុរាដែលនាំគេស្រវឹងលក់ដាច់ណាស់! ពួកគេដឹងហើយថានៅពេលណាអតិថិជន របស់គេមានពិធីអាពាហ៍ពិពាហ៍ថ្ងៃបុណ្យការជប់លៀងឬការប្រកបគ្នាគេនឹងត្រូវការគ្រឿង

ស្រវឹងនោះឯង។ មានមនុស្សតិចណាស់ដែលអាចផឹកស៊ីដូចលោកិយហើយមិនស្រវឹងហេតុនោះហើយបានជារឿងស្រវឹងស្រាជាបញ្ហាធំនៅជុំវិញពិភពលោក។

នៅពេលដែលអ្នកជឿលើព្រះយេស៊ូវអានព្រះគម្ពីរហើយអានពាក្យស្រាកុំឲ្យស្មានថាស្រានៅពេលនោះស្រដៀងគ្នានិងសុរានៅពេលបច្ចុប្បន្នទេ។ ព្រះយេស៊ូវមិនបានប្តូរទឹកក្នុងពាងនៅភូមិកាណានទៅជាស្រាដូចជាស្រាបៀរឬវីស្គីដែលមានលើតុនៅពេលលោកិយស៊ីលៀងរាល់ថ្ងៃនេះទេ។លោកប៉ុលមិនបានបង្ខំឲ្យលោកធីម៉ូថេឲ្យផឹកស្រាសឬស្រាបៀរដូចមានលក់នៅទីផ្សារនៅស្រុកខ្មែរទេ។

តើមានព្រះគម្ពីរណាទៀតដែលជួយនាំយើងឲ្យស្គាល់ព្រះហឫទ័យ នៃទ្រង់ចំពោះការផឹកសុរានោះទេ? មាន!

3. <u>ប្រាជ្ញា</u>

**អ្នកជឿដែលមានប្រាជ្ញាចេះវែកញែកតាមព្រះគម្ពីរជាអ្នកតមពីគ្រឿងស្រវឹង ទោះបីជាចេះផឹកដោយមិនស្រវឹងក៏ដោយ។**

គ្រីស្ទបរិស័ទភាគច្រើនបង្រៀនថាអ្នកជឿលើព្រះយេស៊ូវទាំងឡាយគួរតមគ្រឿងស្រវឹងទោះបីជាចេះផឹកដោយមិនស្រវឹងក៏ដោយ។អ្នកនោះអង្វរអ្នកជឿកុំឲ្យផឹកសុរាជាមួយមិត្តភក្តិនៅពេលដែលជប់គ្នាស៊ីលៀងហើយកុំដាក់សុរានៅពេលការកូនឬមានពិធីឡើងផ្ទះឡើយ។ ប៉ុន្តែមានគ្រីស្ទបរិស័ទមួយចំនួនទៀតប្រកែកថាអ្នកជឿលើព្រះយេស៊ូវមានសេរីភាពដើម្បីផឹកស្រាដូច្នេះគេថាផឹកចុះ។ មានអ្នកខ្លះនាំគ្នាផឹកស៊ីបន្ទាប់ពីពេលថ្វាយបង្គំទៀត។ តើយើងគួរធ្វើតាមអ្នកណា? តើយើងគួរតមគ្រឿងស្រវឹងឬផឹកដោយសេរីភាពកុំតែស្រវឹង?

**មានហេតុការច្រើនដែលគួរនាំគ្រីស្ទបរិស័ទសំរេចចិត្តតមគ្រឿងស្រវឹង។**

1. **គ្រីស្ទបរិស័ទគួរសំរេចចិត្តតមគ្រឿងស្រវឹងពីព្រោះគាត់កោតខ្លាចព្រះ។**
   - **ព្រះស្អប់ការស្រវឹងស្រាហើយព្រមានកូនរបស់ទ្រង់ឲ្យការពារខ្លួនដោយការហ្មត់ចត់ កុំឲ្យស្រវឹងស្រាដូចគេដូចជីវិតចាស់របស់យើងមុនជឿ** (១ពេត្រុស ៤:១-៥; សុភាសិត ២៣:១៩-២១)។ ការដាស់តឿនឱ្យប្រយ័ត្នពីព្រោះព្រះនឹងវិនិច្ឆ័យអស់អ្នកណាដែលស្រឡាញ់ការស្រវឹងស្រា (អេសាយ ៥:១១, ២០-២២)។ក្នុងព្រះគម្ពីរការស្រវឹងស្រាជាភស្តុតាងថា

អ្នកនោះនៅជាប់ក្នុងការបះបោរប្រឆាំងនិងព្រះ។គ្រីស្ទបរិស័ទជាអ្នកដែលមានជីវិតថ្មីក្នុងព្រះអង្គជាអ្នកដែលបានផ្តាច់បាបតាមរយៈព្រះយេស៊ូវ។ សេចក្តីពិតទាំងនេះគួរនាំអ្នកជឿលើទ្រង់គ្រប់គ្នាឲ្យប្រយ័ត្នប្រយែងហើយទៅឆ្ងាយមិនចេះជិតនិងការស្រវឹងស្រា។

- **ព្រះជាម្ចាស់បានបង្គាប់យើងឲ្យចៀសពីមនុស្សណាហើយកាលៈទេសៈណាដ៏នាំយើងជំពប់ដួលក្នុងអំពើបាប។**សវកពេត្រុសប្រាប់យើងថា « *ចូរឲ្យអ្នករាល់គ្នាចៀសពីសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ដែលតយុទ្ធនឹងព្រលឹងវិញ្ញាណចេញ ទាំងប្រព្រឹត្តដោយទៀងត្រង់ នៅក្នុងពួកសាសន៍ដទៃ*» (១ពេត្រុស ២:១១-១២)។នៅកន្លែងណាដែលគេនាំគ្នាញ៉ាំសុរា កាលនោះមានឱកាសដើម្បីបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមច្រើនមានស្រវឹងស្រាជាដើមមានអំពើអាម៉ាស់ការស្រើបស្រាលអំពើហឹង្សានិយាយបែបមិនគប្បីការឈ្លោះគ្នា។ល។ សវកប៉ុលលោកដាស់តឿនយើងថាយើង «*ត្រូវប្រដាប់ខ្លួន ដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ ហើយកុំឲ្យផ្គត់ផ្គង់ ដើម្បីនឹងបំពេញសេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាមឡើយ។*» (រ៉ូម ១៣:១៣-១៤)។ដូច្នេះអ្នកជឿលើព្រះត្រូវកោតខ្លាចហើយគោរពព្រះអង្គដោយមានចិត្តរក្សាខ្លួនកុំឲ្យធ្វើអ្វីដែលធ្វើឲ្យខូចព្រះនាមទ្រង់។យើងគួរខ្លាចអំពើបាប ហើយផលបាបហើយការពារខ្លួនក្រែងលោយើងត្រូវទទួលការដាក់ទោសពីព្រះអង្គមក។ តើយើងអាចការពារខ្លួនកុំឲ្យផ្គត់ផ្គង់សេចក្តីប៉ងប្រាថ្នាសាច់ឈាមរបស់យើងអំពីការស្រវឹងស្រាយ៉ាងមេចបាន? ដោយតមគ្រឿងស្រវឹងដោយការមិនចូលរួមជាមួយគេក្នុងការផឹកស៊ីនេះហើយជាផ្លូវចៀសផុតពីអំពើបាបដើម្បីគោរពព្រះក្នុងភាពបរិសុទ្ធ។

## 2. គ្រីស្ទបរិស័ទគួរសំរេចចិត្តតមគ្រឿងស្រវឹងពីព្រោះគាត់ស្រឡាញ់អ្នកជឿងទៀត

❖ យើងមិនគួរផឹកសុរាពីព្រោះយើងស្រឡាញ់បងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទ។ប្រហែលជាមានអ្នកជឿខ្លះដែលមានការគ្រប់គ្រងលើចិត្តខ្លួនឯងល្មមដែលអាចផឹកស្រាហើយមិនដែលស្រវឹង។អ្នកផឹកសុរាមិនដែលស្រវឹងពិតជាតិចណាស់! បើផឹកដោយមិនស្រវឹងបានតើមានន័យថាគួរញ៉ាំស្រាឬទេ? ទេ! មិនគួរញ៉ាំឡើយ! ហេតុអ្វី? ពីព្រោះអ្នកជឿលើព្រះយេស៊ូវភាគច្រើនមុនដែលជឿលើទ្រង់ជាអ្នកផឹកសុរា ជាអ្នកចំណូលស្រាជាអ្នកប្រមឹកញៀនគ្រឿងស្រវឹង ឬអ្នកដើរលេងស៊ីផឹក ដូច្នេះសុរាជាសេចក្តីល្បួងមួយដ៏ធំសម្រាប់ពួកគាត់។ យើងជាអ្នកជឿព្រះចាស់ហើយរឹងមាំត្រូវធ្វើជាគំរូហើយបង្ហាញដល់អ្នកជឿថ្មី ឬខ្សោយថាអ្នកជឿលើព្រះយេស៊ូវ មិនត្រូវការគ្រឿងស្រវឹង ដើម្បីសប្បាយដូចលោកិយទៀតឡើយ។ យើងត្រូវបង្ហាញគេរបៀបដែលគ្រីស្ទបរិស័ទ «*មិនផ្គត់ផ្គង់ដើម្បីនឹងបំពេញសេចក្តីប៉ងប្រាថ្នា ខាងឯសាច់ឈាម*» (រ៉ូម ១៣:១៣-១៤)។ យើងមិនចង់នាំអ្នកខ្សោយហ៊ានផឹកស្រា ហើយជំពប់ដួលដោយគាត់ឃើញគំរូមិនល្អរបស់យើងនោះទេ។ជូនកាលអ្នកជឿលើទ្រង់ត្រូវចេះលះបង់អ្វីមួយដែលយើងរាប់ជាសិទ្ធិរបស់យើងដើម្បីជួយអ្នកដទៃ។ នេះហើយជាសេចក្តីស្រឡាញ់របស់ព្រះ។

ហេតុការដែលនាំឲ្យគ្រីស្ទបរិស័ទកុំឲ្យបរិភោគម្ហូបសែនគឺជាហេតុការដដែលដែលនាំយើងកុំឲ្យផឹកគ្រឿងស្រវឹង (១កូរិនថូស ជំពូក ៨ និង ១០)។ តើយើងជាពួជជ្រើសរើសរបស់ទ្រង់គួរនាំឲ្យកូនរបស់ព្រះផ្សេងទៀតហ៊ានផឹកសុរា ហើយចាញ់សេចក្តីល្បួងយ៉ាងមេចកើត? យើងត្រូវបង្ហាញពីសេចក្តីស្រឡាញ់របស់យើងទៅកាន់គេហើយតមគ្រឿងស្រវឹងដើម្បី លើកទឹកចិត្តគេឲ្យស្មោះត្រង់និងទ្រង់ ទោះបីជាយើងចេះផឹកដោយមិនស្រវឹងក៏ដោយ។ លោកប៉ុលដាស់តឿនថា «*ហេតុដូច្នេះ បើសិនជាចំណីអាហារអ្វី នាំឲ្យបងប្អូនខ្ញុំជំពប់ដួល នោះខ្ញុំមិន*

*ព្រមទទួលទានចំណីអាហារនោះជាដរាបតទៅ ក្រែងបងប្អូនខ្ញុំជំពប់ដួល។»* ហើយ *«ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរីល្អដល់ព្រះចុះ»* (១កូរិនថូស ៨:១៣ និង ១០:៣១)។

មួយទៀតយើងខ្ញុំចង់សួរលោកអ្នកបន្តិចមើលថាតើលោកអ្នកជាអ្នកជឿលើព្រះយេស៊ូវ អាចសូមព្រះពរមុនចុះទៅស៊ីផឹកជាមួយគេបានឬទេ? តើអ្នកគួរនាំគ្នាញ៉ាំសុរានៅពេលដែលក្រុមជំនុំប្រជុំគ្នា ដើម្បីអធិស្ឋានឬរៀនព្រះគម្ពីរដែរឬទេ? តើលោកអ្នកជាទីស្រឡាញ់របស់យើងខ្ញុំ ក្នុងព្រះគ្រីស្ទអើ! លោកអ្នកឃើញទេ? ការញ៉ាំគ្រឿងស្រវឹងនិងការថ្វាយបង្គំព្រះមិនស៊ីគ្នាឡើយ។ បើយើងស្រឡាញ់បងប្អូនក្នុងព្រះគ្រីស្ទបើយើងចង់ជួយគាត់ឲ្យមានសេរីភាពពីការស្រវឹងស្រាយើងនិងតមពីគ្រឿងស្រវឹង មិនផឹកហើយមានអំណួតថា ចេះផឹកតែមិនស្រវឹងនោះឡើយ។

3. **គ្រីស្ទបរិស័ទគួរសំរេចចិត្តតមគ្រឿងស្រវឹងពីព្រោះគាត់ស្រឡាញ់អ្នកមិនទាន់ជឿ។**

✓ នៅពេលដែលនរណាម្នាក់ទើបទទួលជឿលើព្រះយេស៊ូវ មិនយូរប៉ុន្មានបងប្អូនអ្នកភូមិនិងមិត្តសំឡាញ់ដឹងពីព្រោះអី? ពីព្រោះនៅពេលដែលយើងជឿលើព្រះអង្គជីវិតរបស់យើងចាប់ផ្តើមកែប្រែ។ យើងឈប់ថ្វាយបង្គំរូបព្រះ លេងសែនសំណែន លេងអុជធូប។ល។ ហើយអ្នកជឿថ្មីនោះចាប់ផ្តើមចូលរួមថ្វាយបង្គំព្រះជាមួយអ្នកជឿដូចគ្នាទៅវិញ។ ដូច្នេះនៅពេលដែលគេឃើញការផ្លាស់ប្រែនោះពួកគាត់ពិនិត្យមើលអ្នកជឿនោះដើម្បីមើលឃើញថា ជំនឿនោះពិតឬមិនពិត។អ្នកមិនទាន់ជឿខ្លះគេចង់ដឹងថាតើជំនឿទៅលើព្រះយេស៊ូវ ផ្តល់ជីវិតថ្មីឲ្យអ្នកជឿមែន ឬមិនមែនទេ? បើអ្នកជឿថ្មីនោះគ្មានការកែប្រែពីអំពើបាបទេ នោះគេសន្និដ្ឋាន

ថា ជំនឿជឿលើព្រះយេស៊ូវមិនខុសគ្នាពីសាសនារបស់គេឡើយ ពីព្រោះការប្រព្រឹត្តរបស់គេនៅដដែលៗមានតែទំលាប់ថ្មីប៉ុណ្ណោះ។

- ✓ **ព្រះយេស៊ូវមានបន្ទូលថានគររបស់ទ្រង់ គឺខុសគ្នាពីលោកិយនេះឆ្ងាយណាស់!** នគររបស់ព្រះគឺបរិសុទ្ធហើយប្រជារាស្ត្ររបស់ទ្រង់ត្រូវបរិសុទ្ធ «*ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ*» (១ពេត្រុស ១:១៦) ។ នៅពេលដែលយើងចុះចូលចំពោះព្រះ ហើយចាប់ផ្តើមរស់នៅក្នុងព្រះគុណរបស់ទ្រង់នៅពេលនោះបានជាបងប្អូន និងមិត្តសំឡាញ់មើលឃើញអំណាចរបស់ដំណឹងល្អ។សវកពេត្រុសលោកបង្រៀនយើងថា «*ឱពួកស្ងួនភ្ងាអើយ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឲ្យអ្នករាល់គ្នាចៀសពីសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ដែលតយុទ្ធនឹងព្រលឹងវិញ្ញាណចេញ*» យើងចៀសពីសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមបាន ពីព្រោះព្រះវិញ្ញាណបរិសុទ្ធជួយយើង។ មនុស្សក្រៅពីព្រះគុណរបស់ទ្រង់មិនអាចចៀសពីវាបានទេពីព្រោះពួកគាត់នៅតែជាអ្នកបំរើបាបដដែល។ លោកពេត្រុសមានដំបូន្មានទៀតថា «*ទាំងប្រព្រឹត្តដោយទៀងត្រង់ នៅក្នុងពួកសាសន៍ដទៃ*»(១ពេត្រុស ២:១១-១២)។ ទីបន្ទាល់របស់យើងគ្មានតម្លៃនៅចំពោះអ្នកមិនជឿទេទាល់តែយើងរស់នៅក្នុងជីវិតថ្មីហើយបង្ហាញពីជីវិតថ្មីនោះតាមរយៈភាពបរិសុទ្ធរបស់យើងក្នុងព្រះគ្រីស្ទ។ បើសិនជាយើងស្រឡាញ់គាត់មែនយើងនិងមានចិត្តមួយថាចង់រស់នៅតាមសេចក្តីពិតហើយនាំគេឲ្យធ្វើដូចគ្នាប៉ុន្តែបើជីវិតរបស់យើងប្រឡាក់ក្នុងបាបដូចគេនោះយើងនាំគេជឿមិនបានទេ។ ការផ្តាច់ពីគ្រឿងស្រវឹងជាការបញ្ជាក់យ៉ាងច្បាស់ថាដំណឹងល្អរបស់ព្រះគ្រីស្ទមានអំណាចមែន។ សាសនាប្រាប់គេកុំឲ្យផឹកប៉ុន្តែសាសនាគ្មានលទ្ធភាពនាំគេផ្តាច់ពីការស្រវឹងសុរាបានទេ។

✓ តើបើសិនជាពួកគ្រីស្ទានចូលរួមផឹកស៊ីជាមួយមិត្តភក្តិនោះសំដែងឲ្យមិត្តភក្តិជាអ្នកមិនជឿព្រះឲ្យស្គាល់ពីភាពបរិសុទ្ធរបស់ព្រះបានដែរឬទេ? បើយើងផឹកស៊ីជាមួយគេដែលកំពង់តែផឹកស្រវឹងនៅពេលថ្ងៃជប់លៀង តើយើងបង្ហាញពីជីវិតថ្មីរបស់យើងក្នុងព្រះយេស៊ូវទៅកាន់អ្នកដែលអង្គុយនៅតុជាមួយយើងយ៉ាងមេចកើត? អ្នកកាន់សាសនាអីស្លាម និងពុទ្ធសាសនាជឿតាមសាសនារបស់គេគ្រប់ៗគ្នា ថាផឹកគ្រឿងស្រវឹងបាប ដូច្នេះនៅពេលដែលគាត់ហ៊ានផឹកខុសអំពីសាសនារបស់ខ្លួនគាត់ដឹងហើយថាខ្លួនប្រព្រឹត្តបាបហើយ។ ចុះបើអ្នកជឿព្រះយេស៊ូវផឹកស្រាជាមួយគេនោះតើអ្នកជឿព្រះយេស៊ូវបង្ហាញគេថាសាសនាព្រះគ្រីស្ទល្អជាជាងដែរឬទេ? ដោយហេតុទាំងអស់នេះចូរឲ្យយើងទាំងអស់គ្នាផ្តាច់ពីការផឹកគ្រឿងស្រវឹងចុះ!

## ការពិចារណានៅទីបញ្ចប់

តើហេតុអ្វីបានជាបញ្ហានេះពិបាកដោះស្រាយច្រើនម្ល៉េះ? អ្នកជឿមានព្រះគម្ពីរដូចគ្នា ប៉ុន្តែអ្នកខ្លះនៅតែប្រកាន់សិទ្ធិផឹកសុរាតើហេតុអ្វីគ្រឿងស្រវឹងសំខាន់ម្ល៉េះនៅចំពោះខ្លួនគាត់? យើងខ្ញុំគិតថា **យ៉ាងហោចណាស់មានហេតុ៤ដែលនាំអ្នកខ្លះមិនព្រមផ្តាច់ការផឹកស្រា :**

1) **អ្នកខ្លះស្រឡាញ់ការស្រវឹងស្រា**ហើយគ្មានចិត្តផ្តាច់វាគ្មានហេតុការណាមួយដែលអាចនាំចិត្តពួកគេចង់ចៀសពីការស្រវឹងបានទេ។ អ្នកណាដែលមានចិត្តបែបនេះ មិនទាន់កែប្រែចិត្តជឿព្រះយេស៊ូវទេ។ ខ្លះក៏ញៀនវាគ្មានចិត្តផ្តាច់បាបនោះទេ។
2) **អ្នកខ្លះធ្លាប់ពឹងទៅលើគ្រឿងស្រវឹងយូរមកហើយដើម្បីស្ងប់ចិត្ត ធូរអារម្មណ៍ ឬភ្លេចពីបញ្ហាក្នុងជីវិត។** គាត់ប្រហែលជឿលើព្រះហើយ ប៉ុន្តែ

គាត់មិនទាន់ចេះទុកចិត្តលើទ្រង់ទេ គាត់ពឹងទៅលើសុរាវិញ ហើយប្រើវាដើម្បីបន្ថយស្រ្តេស។ អ្នកនេះញានគ្រឿងស្រវឹងដែរប៉ុន្តែខាងផ្លូវចិត្តវិញ។

3) **មានគ្រីស្ទបរិស័ទមួយជំនួនដែលមានអំណួតហើយអួតថាគាត់ជាអ្នកជឿដែលមានកម្លាំងហើតញ៉ាំសុរាបាន** ពីព្រោះគាត់ផឹកដោយមិនស្រវឹងបាន គាត់គ្រប់គ្រងលើចិត្តខ្លួនឯងបាន ដូច្នេះគាត់សន្និដ្ឋានថាគាត់ផឹកបាន គាត់មិនខុសទេ។ អ្នកដែលមានចិត្តនោះភាគច្រើន មិនដែលស្តាប់យើងទេ ទោះបីជាយើងបើកព្រះគម្ពីរច្រើនដើម្បីនាំគាត់យល់ដល់អ្នកដទៃក៏ដោយ។

4) **មានពួកគ្រីស្ទានទៀតមួយចំនែកដ៏ធំជាពិសេសបុរសដែលខ្លាចការបៀតបៀន។** អ្នកជឿនោះគាត់ដឹងថាបើឈប់ផឹកស៊ីជាមួយគេគេពិតជានឹងមានការបៀតបៀនពីព្រោះក្នុងលោកិយបុរសសឹងតែនាំគ្នាផឹកគ្រប់ពេលដែលមានការប្រជុំថ្ងៃបុណ្យ ឬជប់លៀង។ គាត់មិនចង់ឲ្យគេមើលងាយ មិនចង់បាត់មិត្ត ហើយជូនកាលខ្លាចមេទៀត ដូច្នេះគាត់សុខចិត្តនៅស្ងៀម ហើយខំផឹកតិចមើលទៅដូចធម្មតាដើម្បីកុំឲ្យគេនិយាយកុំឲ្យខ្មាសគេ។ អ្នកដែលធ្វើដូច្នោះខ្លាចមនុស្សជាជាងខ្លាចព្រះលទ្ធផលទីបន្ទាល់អ្នកនោះតែងតែខ្សោយ។

ព្រះគម្ពីរកណ្ឌ ១ពេត្រុស មានការដាស់តឿនច្រើនសម្រាប់អ្នកដែលខ្លាចការបៀតបៀន ។សវកពេត្រុសពន្យល់អំពីរបៀបដែលព្រះយេស៊ូវបានទទួលការអាមាសខ្មាសហើយការរងទុក្ខយ៉ាងធ្ងន់ធ្ងរដោយការបន្ទាបខ្លួននៅលើឈើឆ្កាង។ ដោយសេចក្តីស្រឡាញ់ព្រះជាម្ចាស់បានទទួលទោសរបស់យើងរាល់គ្នានៅលើរូបកាយទ្រង់ដែលជាប់ឈើឆ្កាងនោះ (១ពេត្រុស ២:២១-២៥)។ យើងត្រូវដើរតាមគំរូល្អបំផុត នោះហើយគោរពទ្រង់ ក្នុងការដឹងគុណហើយមានចិត្តហ៊ានទទួលការបៀតបៀនថ្វាយដល់ព្រះអង្គ (១ពេត្រុស ៣:៨-១៧)។ បើសិនជាយើងធ្វើតាម
គំរូរបស់ព្រះអង្គហើយខំរស់នៅក្នុងភាពបរិសុទ្ធដូចទ្រង់អ្នកមិនជឿខ្លះពិតជានឹងមើលងាយយើង ពីព្រោះគាត់មិនទាន់យល់ថាយើងមិនត្រូវការអំពើបាប ដើម្បីសប្បាយដូច

គេទៀតទេហេតុនេះហើយគេប្រមាថដល់យើង (១ពេត្រុស ៤:១-៦)។ អ្នកជឿលើព្រះមិនគួរឆ្ងល់អំពីការបៀតបៀននោះទេ ហើយត្រូវ ទទួលការបៀតបៀននោះជាចំណែករបស់យើងក្នុងការរងទុក្ខរបស់ព្រះយេស៊ូវវិញ។ នៅពេលដែលព្រះអង្គយាងមកជាលើកទីពីរយើងនឹងទទួលរង្វាន់របស់យើងនៅពេល នោះ ហើយយើងនឹងសប្បាយរីករាយដែលយើងបានស្មោះត្រង់និងព្រះអង្គ (១ពេត្រុស ៤:១២-១៩)។

**អ្នកជឿលើព្រះយេស៊ូចទាំងអស់គ្នាគួរសំរេចចិត្តតមគ្រឿងស្រវឹងមានហេតុធំ៣គឺ :**

1. គាត់យល់អំពី**ការយល់ច្រឡំ** ក្នុងអត្ថាធិប្បាយរបស់អ្នកជឿខ្លះ
2. គាត់មាន**ការយល់ដឹង** អំពីការខុសគ្នារវាងស្រាទំពាំងបាយជូរក្នុងព្រះគម្ពីរនិងគ្រឿងស្រវឹងនៅសម័យនេះ
3. គាត់មាន**ប្រាជ្ញា** គាត់ចេះការពារជំនឿរបស់ខ្លួន យល់ដល់អ្នកដទៃទៀត ទាំងអ្នកជឿទាំងអ្នកមិនជឿផង គាត់រស់នៅក្នុងសេចក្តីស្រឡាញ់នៃព្រះ

*«ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរីល្អដល់ព្រះចុះ» (១កូរិនថូស ១០:៣១)*